

# ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត

វគ្គ៖

## ទូធំ ក្ដោងធំ

FIRST FINANCE


ហាន់នី!
ថ្ងៃនេះមិនចាំបាច់
ធ្វើបាយទេអូន យើង
នាំកូនទៅញ៉ាំអីនៅ
ខាងក្រៅ!


អូនសុំនិយាយ
រឿងមួយសិន មុន
យើងទៅ បានទេ
លោកប្តី?!
មានរឿង
អីហ្នឹងអូន?!
...ចាប់តាំង
ពីលោកប្តីឡើង
តំណែងមក ចំណូល
របស់យើងច្រើន
ជាងមុន...


...តែពេល
អូនទៅ
មើលចំណាយក៏
កាន់តែច្រើនតាម
ហ្នឹងដែរ...

រីឯប្រាក់សន្សំបែជា
ថយុចុះទៅវិញ បើ
ធៀបមុនពេល
លោកប្ដី ឡើង
តំណែង


បើទូកធំ នោះក្ដោងក៏ត្រូវតែធំតាមហ្នឹងដែរហើយអូន
កុំអីចឹងអីបង ពាក្យ **ទូកធំ ក្ដោងធំ** មិនគួរប្រើជាមួយលុយទេ លោកប្ដី បើមិនអីចឹង យើងពិបាកហើយ


អីចឹងក៏បានដែរ តាមអូនចុះ តែកុំតឹងតែងពេក អូនសម្លាញ់!
ចា៎! ឲ្យតែគ្រប់ផែនការ

## ចំណុចគួរចងចាំ

- ត្រូវប្រកាន់ខ្ជាប់នូវវិន័យក្នុងការចាយវាយ បើទោះបីជាចំណូលមានការកើនឡើងបែបណាក៏ដោយ ។
- កែប្រែផែនការហិរញ្ញវត្ថុរបស់លោកអ្នក ដោយបន្ថែមប្រាក់ចំណូលចូលទៅកាន់ខ្ទង់នីមួយៗនិងបន្ថយរយៈពេលក្នុងការសម្រេចផែនការទាំងនោះឲ្យបានខ្លីជាងមុនបើអាច ដូចជាផែនការរំលោះដើម ឬបង់ផ្តាច់កម្ចីគួរតែធ្វើឡើងឲ្យបានឆាប់ជាងមុន នៅពេលចំណូលមានការកើនឡើង ។



**ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសារអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារ ដំណើរការដាក់ស្នើកម្ចី ផលិតផលកម្ចី និងសារអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធភាព ។

យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។

ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់

ហ្វឹស ហ្វាយនែន ឬតាមរយៈអ៊ីម៉ែល

infor@firstfiance.com.kh យើងខ្ញុំនឹងពិនិត្យ ហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទ ឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអានផ្សេងទៀត ។

នាំមកជូនដោយ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី

FIRST FINANCE

គេហទំព័រ ហ្វឹស ហ្វាយនែន
www.firstfinance.com.kh